# ព្រឹត្តិបត្រ មេធាវី

# BULLETIN METHEAVY

ប្រចាំឆមាស ខែមករា-មិថុនា ឆ្នាំ២០២៣ លេខ២៨

## យុត្តិធម៌ និង ច្បាប់

## JUSTICE AND LAW



ការផ្សាយរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានអគារកាច់ជ្រុងផ្លូវលេខ ១១២៩ កែងផ្លូវ ១៩៣០
សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (៨៥៥-២៣) ៦២២ ៧០៧០
អ៊ីម៉ែល info@bakc.org.kh
គេហទំព័រ bakc.org.kh

រួមគ្នាដើម្បីឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី

www.theflaglawyer.com

# ច្បាប់ស្ដីពីសំណង់
# និងទំនួលខុសត្រូវចំពោះករណីសំណង់នាំឱ្យខូចខាតដល់តតិយជន

# Construction Law and Liability for Any Damage Caused to Any Person

# ច្បាប់ស្ដីពីសំណង់ និងទំនួលខុសត្រូវ ចំពោះករណីសំណង់នាំឱ្យខូចខាតដល់តតិយជន

ដោយលោកមេធាវី **ផន ឈៀងឡេង***

## ១.សេចក្ដីផ្ដើម

វិស័យសំណង់ ជាវិស័យដ៏សំខាន់មួយដែលជួយទ្រទង់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាវិស័យមួយដែលជួយលើកមុខមាត់ព្រះរាជាណាចក្រកម្ពុជា ជួយទាក់ទាញអ្នកវិនិយោគជាតិ និងអន្តរជាតិជាច្រើនផងដែរ នាពីរទសវត្សចុងក្រោយនេះ។ ការអភិវឌ្ឍវិស័យនេះ ក៏បានជួយលើកស្ទួយដល់ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋខ្មែរទាំងឱកាសការងារ ការប្រកបអាជីវកម្ម ព្រមទាំងជួយលើកកម្ពស់បច្ចេកទេសសាងសង់ក្នុងផ្នែកស្ថាបត្យកម្ម និងវិស្វកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងការអភិវឌ្ឍខ្លាំងក្នុងវិស័យសំណង់នេះ យើងឃើញមានបញ្ហាប្រឈមមួយចំនួនតែងតែកើតមានឡើង ទាំងក្នុងអំឡុងពេលសាងសង់ និងក្រោយការសាងសង់។ ជាក់ស្ដែងមានគម្រោងអភិវឌ្ឍខ្លះបង្កគ្រោះថ្នាក់ដល់កម្មករសំណង់ អ្នកសាងសង់ អ្នកប្រើប្រាស់សំណង់ អ្នកជិតខាងក៏ដូចជាសាធារណជនទូទៅ។ កន្លងមកក៏មានការធ្លាក់សម្ភារៈសំណង់ គ្រឿងបង្គុំសំណង់ផ្សេងៗពីលើសំណង់អគារមកខាងក្រោមដែលនាំឱ្យប៉ះពាល់ដល់សម្ភារៈប្រើប្រាស់ ករណីខ្លះរហូតដល់មានរបួសស្នាម និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដែលអាចប៉ះពាល់ដល់អាយុជីវិតសាធារណជនទូទៅ។ ករណីការអភិវឌ្ឍ និងការសាងសង់នេះមានការធ្វេសប្រហែស ឬគ្រប់គ្រងពុំបានល្អស្របតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច លក្ខខណ្ឌបច្ចេកទេសសំណង់ និងពុំគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

ហេតុដូចនេះ យើងសង្កេតឃើញរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យសំណង់នេះ ដោយលិខិតបទដ្ឋានគតិយុត្តជាច្រើន និងជាបន្តបន្ទាប់ត្រូវបានរាជរដ្ឋាភិបាលរៀបចំតាក់តែង ហើយបានអនុម័តដាក់ឱ្យអនុវត្ត ក្នុងគោលបំណងដើម្បីធានាសោភណភាពនិងគុណភាពល្អនៃសំណង់ សម្រាប់ឱ្យប្រជាពលរដ្ឋប្រើប្រាស់ និងរស់នៅប្រកបដោយចីរភាព ដើម្បីបង្កើនការយកចិត្តទុកដាក់លើការប្រកបការងារ ការប្រកបវិជ្ជាជីវៈក្នុងវិស័យ

---

* លោកមេធាវី **ផន ឈៀងឡេង** មេធាវីនៃក្រុមមេធាវី ដឹហ្វ្លេក និងជាមជ្ឈត្តករផ្នែកពាណិជ្ជកម្មនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

សំណង់ ជានាសន្តិសុខ សុវត្ថិភាព ការពារទ្រព្យសម្បត្តិ សុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជនទូទៅ។ ច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានតម្រូវឱ្យគ្រប់ម្ចាស់សំណង់ទាំងអស់ ត្រូវមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ទាំងសំណង់ចាស់ ទាំងសំណង់ថ្មី ដោយគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាននានាដែលពាក់ព័ន្ធនឹងវិស័យសំណង់។ ករណីម្ចាស់សំណង់ណាមួយប្រើប្រាស់ ឬចាត់ចែងសំណង់របស់ខ្លួនទាំងពុំទាន់មានវិញ្ញាបនបត្រប្រើប្រាស់សំណង់នេះ នឹងត្រូវទទួលទណ្ឌកម្ម ដូចជាការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់តែម្តង ហើយថែមទាំងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងចំពោះអ្នកដទៃផងដែរ ក្នុងករណីការប្រើប្រាស់ និងចាត់ចែងរបស់ខ្លួន នាំឱ្យប៉ះពាល់សន្តិសុខសុវត្ថិភាព និងអាយុជីវិតរបស់បុគ្គលណាមួយ។

ការស្រាវជ្រាវនេះមានគោលបំណងសិក្សាអំពីសកម្មភាពល្មើស វិធានការរដ្ឋបាល និងទោសទណ្ឌ ក៏ដូចជាចំណាត់ការផ្លូវច្បាប់នានាចំពោះម្ចាស់សំណង់ អ្នកសាងសង់ អ្នកគ្រប់គ្រងសំណង់ ដែលបានប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងសំណង់របស់ខ្លួន ពុំស្របតាមច្បាប់ស្តីពីសំណង់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងវិស័យសំណង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.គោលការណ៍ច្បាប់ស្តីពីសំណង់ និងវិធានការតាមផ្លូវច្បាប់ចំពោះការខូចខាតនានាក្នុងវិស័យសំណង់

ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់បុគ្គលម្នាក់ៗ ទាំងក្នុងស្ថាប័នសាធារណៈ ទាំងក្នុងស្ថាប័នឯកជន មានបុគ្គល ឬអ្នករាជការសាធារណៈ ដែលអនុវត្តបានពេញលេញ និងខ្ជាប់ខ្ជួនតាមតួនាទី និងភារកិច្ចរបស់ខ្លួន ហើយក៏មានបុគ្គល ឬអ្នករាជការសាធារណៈមួយចំនួន ពុំគោរពតាមតួនាទី និងភារកិច្ចតាមដែនសមត្ថកិច្ចរបស់ខ្លួន ដែលច្បាប់និងស្ថាប័នរបស់ខ្លួនបានកំណត់។ ជាការឆ្លើយតប ដើម្បីធានាលើការអនុវត្តតួនាទីនេះឱ្យបានត្រឹមត្រូវ យើងសង្កេតឃើញមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនបានកំណត់អំពីការដាក់វិន័យរដ្ឋបាល និងការដាក់ទោសទណ្ឌនានាទៅលើបុគ្គល ឬអ្នករាជការសាធារណៈ ដែលពុំអនុវត្ត ឬអនុវត្តខុស ឬហួសពីតួនាទីភារកិច្ចរបស់ខ្លួន។ តាមការស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យសំណង់នេះ យើងឃើញថា វិធានការជាច្រើនត្រូវបានធ្វើឡើងដោយឡែកៗពីគ្នា ដោយអាស្រ័យលើប្រភេទការងាររបស់

បុគ្គល ឬស្ថាប័ននីមួយៗនោះ។ ដូច្នេះយើងនឹងសិក្សាជារួមអំពីការដាក់វិធានការ និងទណ្ឌកម្មនានា ដោយចែកជា ៣ ផ្នែក រួមមាន៖

i). វិធានការចំពោះមន្ត្រីអនុវត្តច្បាប់

ii). វិធានការចំពោះអ្នកអភិវឌ្ឍអចលនវត្ថុនិងអ្នកកាន់វិជ្ជាជីវៈ

iii). វិធានការចំពោះម្ចាស់សំណង់ អ្នកសាងសង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជនទូទៅ។

## ២.១.វិធានការចំពោះមន្ត្រីអនុវត្តច្បាប់

រាល់ការសាងសង់ ឬការអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យមានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណត្រឹមត្រូវចេញដោយអាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកតាមជំនាញបច្ចេកទេសនីមួយៗក្នុងវិស័យសំណង់ ដូចជាលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតអភិវឌ្ឍដី អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ លិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ ឬសិក្សាគម្រោងប្លង់ និងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុ។ល។ ឯកសារផ្លូវច្បាប់នេះគឺពិតជាចាំបាច់ សម្រាប់គាំទ្រដល់ការអភិវឌ្ឍនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឱ្យបាននូវការអនុវត្តច្បាប់ ក៏ដូចជាធានាដល់ការអភិវឌ្ឍគម្រោងសាងសង់ឱ្យមានភាពស៊ីចង្វាក់គ្នាស្របតាមគោលការណ៍អភិវឌ្ឍ និងស្តង់ដារបច្ចេកទេសសំណង់ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ហើយដែលមន្ត្រីអនុវត្តច្បាប់ ជាបុគ្គលចម្បងក្នុងការអនុវត្តនិងធានាឱ្យបាននូវការគោរពបទប្បញ្ញត្តិច្បាប់ជាធរមាននេះ។

ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ បានកំណត់ជាក់លាក់អំពីការដាក់វិធានការចំពោះអ្នករាជការសាធារណៈណាដែលពុំគោរពតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក៏ដូចជាពុំគោរពតាមការណែនាំ និងគោលការណ៍ក្នុងការអនុវត្តតួនាទី និងភារកិច្ចទៅតាមដែនសមត្ថកិច្ច និងស្ថាប័នជំនាញរបស់ខ្លួន។ ជាក់ស្តែងមាត្រា ៣៨ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា នេះបានចែងថា *«...អ្នករាជការទាំងអស់ត្រូវទទួលខុសត្រូវពីកំហុស និងការធ្វេសប្រហែសក្នុងវិជ្ជាជីវៈ ព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន»* ហើយដែលកំហុស និងការធ្វេសប្រហែសក្នុងវិជ្ជាជីវៈនេះ ត្រូវយកទណ្ឌកម្មខាងវិន័យរួមមាន ការស្តីបន្ទោស ការស្តីបន្ទោសដោយមានចំណារក្នុងលិខិត លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ ដាក់ឱ្យនៅទំនេរគ្មាន

ប្រាក់បៀវត្សមិនឱ្យលើសពីមួយឆ្នាំ បន្ថយឋានន្តរស័ក្តិ ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ មកអនុវត្តចំពោះអ្នករាជការសាធារណៈ។

លើសពីនេះទៀត អនុក្រឹត្យស្តីពីការកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ បានដាក់វិធានការដល់អ្នករាជការសាធារណៈ ដែលពុំទទួលពិនិត្យសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ឬបដិសេធផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយគ្មានមូលហេតុត្រឹមត្រូវគឺត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល ដោយពុំទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ស្របតាមបញ្ញត្តិក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ដោយឡែកសម្រាប់អ្នករាជការសាធារណៈណាដែលកំពុងមានបញ្ហា និងមានការប្តឹងផ្តល់ចោទប្រកាន់ទៅកាន់តុលាការ នោះអ្នករាជការសាធារណៈនេះ អាចនឹងត្រូវបានផ្អាកពីមុខងាររបស់ខ្លួនជាបណ្តោះអាសន្នសិន ហើយបើករណីអ្នករាជការសាធារណៈត្រូវបានផ្តន្ទាទោសបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយឥតព្យួរទោស នោះនឹងឈានដល់ការហូតងាររបស់អ្នករាជការសាធារណៈតែម្តងដោយគិតពីថ្ងៃសាលក្រមចូលជាស្ថាពរ។[1] ក្នុងន័យនេះហើយដែលអ្នករាជការ សាធារណៈ (ឬមន្ត្រីអនុវត្តច្បាប់) ត្រូវមានការប្រុងប្រយ័ត្ន ចំពោះការអនុវត្តភារកិច្ចរបស់ខ្លួន ព្រោះថាជនរងគ្រោះ ដែលទទួលរងផលប៉ះពាល់ពីសកម្មភាពរបស់មន្ត្រីអនុវត្តច្បាប់នេះមានសិទ្ធិក្នុងការប្តឹងមន្ត្រីអនុវត្តច្បាប់ ក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងៗទៀត ករណីដែលមន្ត្រីអនុវត្តច្បាប់ ឬអ្នកពាក់ព័ន្ធនោះបានអនុវត្តភារកិច្ចរបស់ខ្លួនផ្ទុយពីច្បាប់កំណត់ និងអនុញ្ញាត។

ដូច្នេះជារួម ករណីមានមន្ត្រីអនុវត្តច្បាប់ណាម្នាក់បំពេញកិច្ចការងារ ឬតួនាទីរបស់ខ្លួនផ្ទុយពីគោលការណ៍ណែនាំរបស់ស្ថាប័នជំនាញ ឬបទប្បញ្ញត្តិច្បាប់ជាធរមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន នោះមន្ត្រីអនុវត្តច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះស្ថាប័នជំនាញរបស់ខ្លួនផង និងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយថែមទាំងអាចត្រូវទទួលទោសផ្នែកព្រហ្មទណ្ឌផងដែរចំពោះអំពើល្មើសរបស់ខ្លួន។

[1] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤, ម.៥២ និង ម.៥៣

## ២.២.វិធានការចំពោះអ្នកអភិវឌ្ឍអចលនវត្ថុ និងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ទាំងអស់ រួមទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យសំណង់ក្តី ត្រូវមានលិខិតអនុញ្ញាតត្រឹមត្រូវសម្រាប់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយអ្នកវិជ្ជាជីវៈក៏អាចនឹងបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនផងដែរ ក្នុងករណីអ្នកវិជ្ជាជីវៈ លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ ឬប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាក ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញ ឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ ទទួលការប្រកាសក្ស័យធនដោយតុលាការ ឬធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនាពេលកន្លងមក។[2] ក្នុងន័យនេះអាចបញ្ជាក់បានថា អ្នកប្រកបអាជីវកម្ម និងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបំពេញការងាររបស់ខ្លួនឱ្យបានល្អ និងត្រឹមត្រូវតាមបញ្ញត្តិច្បាប់ជាធរមាន ពុំត្រូវអនុវត្តការងារណាមួយខុស ឬហួសពីច្បាប់តម្រូវ ឬតួនាទីវិជ្ជាជីវៈរបស់ខ្លួនឡើយ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់នេះ អាចផ្អាករហូតរយៈពេល ៦ ខែ គិតពីថ្ងៃផ្អាកអាជ្ញាបណ្ណនោះ ឬឈានដល់ការដកហូតអាជ្ញាបណ្ណ ក្នុងករណីអ្នកកាន់វិជ្ជាជីវៈបន្តពុំគោរពតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ឬបទប្បញ្ញត្តិច្បាប់ជាធរមាន។

សម្រាប់គម្រោងសាងសង់ ឬគម្រោងការអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការសាងសង់បុរី អគារសហកម្មសិទ្ធិ ផ្ទះល្វែង ឬការពុះដីឡូត៍ជាដើម គឺតម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាដល់ការអភិវឌ្ឍឱ្យមានភាពត្រឹមត្រូវ និងស្របតាមលក្ខណៈបច្ចេកទេសសំណង់ និងស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។ ក្រោយទទួលបានលិខិតអនុញ្ញាតអភិវឌ្ឍដីនេះ អ្នកអភិវឌ្ឍក៏ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ស្របតាមនីតិវិធីច្បាប់ជាធរមានផងដែរ ករណីគម្រោងអភិវឌ្ឍរបស់ខ្លួន ជាគម្រោងសាងសង់ផ្ទះល្វែង បុរី ឬអគារសហកម្មសិទ្ធិជាដើម។

ច្បាប់ស្តីពីសំណង់ ចុះថ្ងៃ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ និងប្រកាសលេខ ០៨៧ ស្តីពីការអភិវឌ្ឍដី ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ កំណត់ថាការអភិវឌ្ឍដីទាំងឡាយដោយគ្មាន

---

[2] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ម.១៦ ។

លិខិតអនុញ្ញាតអភិវឌ្ឍដីពីអាជ្ញាធរមានសមត្ថកិច្ច ការប្រើប្រាស់លិខិតអនុញ្ញាតអភិវឌ្ឍដីហួសសុពលភាព ការអភិវឌ្ឍដីខុសពីលិខិតអនុញ្ញាត ការផ្ទេរលិខិតអនុញ្ញាតអភិវឌ្ឍដីដោយគ្មានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច ការបង្ហាញផ្ទាំងសញ្ញាគម្រោងអភិវឌ្ឍដីខុសពីគំនូរប្លង់ប្រើប្រាស់ដីដែលទទួលបានការអនុញ្ញាត ពុំអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច និងពុំគោរពតាមលក្ខខណ្ឌ និងកិច្ចការងាររបស់ខ្លួន ស្របតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងវិស័យសំណង់ គឺត្រូវទទួលរងទណ្ឌកម្ម ដូចជាការព្រមានជាលាយលក្ខណ៍អក្សរ ការបង្ខំឱ្យរៀបចំដីឱ្យដូចសភាពដើមវិញ ការផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាន ការដាក់ពិន័យអន្តរការណ៍ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានបាន។ ការដាក់ទណ្ឌកម្មនេះ អាជ្ញាធរអាចសម្រេចដាក់ទណ្ឌកម្មណាមួយ ឬច្រើនទៅតាមអំពើដែលអ្នកអភិវឌ្ឍបានប្រព្រឹត្ត។

បន្ថែមលើទណ្ឌកម្មខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិពេញលេញក្នុងការចងក្រងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច និងអាចសម្រេចសុំរឹបអូសសម្ភារៈ បរិក្ខារ និងឧបករណ៍ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអំពើល្មើស ករណីអ្នកអភិវឌ្ឍទទួលទណ្ឌកម្មខាងលើនេះ ពុំព្រមអនុវត្តតាមសេចក្តីសម្រេចណាមួយរបស់អាជ្ញាធរមានសមត្ថកិច្ច។

**សម្រាប់ការធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុ៖** រាល់ការធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានការអភិវឌ្ឍសាងសង់បុរី អគារសហកម្មសិទ្ធិ ផ្ទះល្វែង ឬការពុះដីឡូត៍ជាដើម ដែលធ្វើក្នុងគោលបំណងសម្រាប់លក់ ឬជួលរយៈពេលវែង គឺតម្រូវឱ្យមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអភិវឌ្ឍអចលនវត្ថុពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ទើបអ្នកអភិវឌ្ឍអាចដំណើរការលក់ ឬជួលគម្រោងអាជីវកម្មអភិវឌ្ឍរបស់ខ្លួនបាន។[3]

ករណីអ្នកអភិវឌ្ឍធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ដោយគ្មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ឬក្លែងបន្លំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ប្រើប្រាស់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតហួសសុពលភាព ឬពុំអនុវត្តតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច និងច្បាប់ជាធរមាន នោះអ្នកអភិវឌ្ឍត្រូវទទួលរងទណ្ឌកម្មផ្នែករដ្ឋបាល ដូចជាការព្រមានជាលាយលក្ខណ៍អក្សរ ការបង្កកគណនីអភិវឌ្ឍអចលនវត្ថុ ការហាមឃាត់ធ្វើប្រតិបត្តិការសកម្មភាពអាជីវកម្ម ការព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតសាងសង់ ការពិន័យជាប្រាក់ ហើយអាចឈានដល់ការប្តឹងទៅតុលាការមានសមត្ថកិច្ចផងដែរ។ អ្នកអភិវឌ្ឍអចលនវត្ថុ ក៏ត្រូវទទួលខុសត្រូវចំពោះអ្នកដទៃដែលរងគ្រោះថ្នាក់

[3] ប្រកាសលេខ ០៨៩ ស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។



www.theflaglawyer.com

ដោយសារគម្រោងអភិវឌ្ឍរបស់ខ្លួន ករណីរកឃើញថាកំហុសដែលកើតឡើងនោះគឺដោយសារការធ្វេសប្រហែស ឬបណ្តាលមកពីសកម្មភាពរបស់អ្នកអភិវឌ្ឍ។

**សម្រាប់ការត្រួតពិនិត្យនិងបញ្ជាក់សំណង់៖** ក្នុងវិស័យសំណង់នេះ ការត្រួតពិនិត្យ និងបញ្ជាក់គុណភាពរបស់សំណង់ ជាការចាំបាច់ត្រូវតែមាននិងពុំអាចខ្វះបានចំពោះសំណង់គ្រប់ប្រភេទ ដើម្បីអាចជួយបង្ការនូវបញ្ហាគ្រោះថ្នាក់ណាមួយដែលកើតមានជាយថាហេតុ និងការពារសុខសុវត្ថិភាពដល់ម្ចាស់សំណង់ ក៏ដូចជាភាគីអ្នកពាក់ព័ន្ធផ្សេងៗទៀត ព្រោះថាការត្រួតពិនិត្យនិងបញ្ជាក់សំណង់នេះ គឺត្រូវបានធ្វើឡើងដោយអ្នកវិជ្ជាជីវៈត្រឹមត្រូវ និងមានសមត្ថភាពច្បាស់លាស់ក្នុងវិស័យសំណង់។ លើសពីនេះទៀត ករណីអ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ពុំគោរពតាមលក្ខខណ្ឌការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់តាមច្បាប់តម្រូវ និងតាមតួនាទីភារកិច្ចរបស់ខ្លួនទេ នោះត្រូវទទួលរងវិធានការទណ្ឌកម្ម ដូចជាកាព្រមានជាលាយលក្ខណ៍អក្សរ ឬឈានដល់ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់តែម្តង។[4]

អាជ្ញាធរមានសមត្ថកិច្ច ត្រូវព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់នេះ ក្នុងរយៈពេល ៦ខែ ចំពោះអ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ ឬរយៈពេល ១ឆ្នាំ ចំពោះអ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណពុំគោរពតាមលក្ខខណ្ឌការងារប្រកបវិជ្ជាជីវៈរបស់ខ្លួនមិនគោរពតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច។ ករណីអ្នកកាន់អាជ្ញាបណ្ណនៅតែពុំអនុវត្តតាមការណែនាំ ដូចកំណត់ក្នុងសេចក្តីសម្រេចស្តីពីការព្យួរអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬអ្នកកាន់អាជ្ញាបណ្ណ នៅតែបន្តប្រព្រឹត្តខុសធ្ងន់ធ្ងរចំពោះក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់ ឬបទប្បញ្ញត្តិច្បាប់ជាធរមាន នោះអាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិសម្រេចដកហូតអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ពីអ្នកកាន់អាជ្ញាបណ្ណនេះតែម្តង។

ជារួមយោងតាមច្បាប់ស្តីពីសំណង់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យសំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវទទួលខុសត្រូវសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃដែលរងផលប៉ះពាល់ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន ករណីពុំបានអនុវត្តកិច្ចការងារបានត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេសសំណង់។ អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ដែលបានបញ្ជាក់លើគម្រោងប្លង់ ឬការងារសាងសង់ឬរុះរើថាត្រឹមត្រូវ ខណៈតាមស្ថានភាពជាក់ស្តែង គម្រោងប្លង់ ឬការងារសាងសង់ ឬរុះរើនោះ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស

---

[4] អនុក្រឹត្យលេខ ២២៥ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។

សំណង់ និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយថែមទាំងបង្កឱ្យមានរបួសស្នាម ឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃទៀត នោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៣០ លានរៀល ទៅ ៦០ លានរៀល។

**សម្រាប់អ្នកប្រកបអាជីវកម្មសាងសង់ និងសិក្សាគម្រោងប្លង់៖** ក្នុងអំឡុងពេលនៃការបំពេញការងាររបស់ខ្លួន អ្នកសិក្សាគម្រោងប្លង់ និងសាងសង់ ដែលទទួលបានលិខិតអនុញ្ញាតត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ចនោះ ត្រូវទទួលខុសត្រូវសងការខូចខាតនានាដែលកើតមានដល់អ្នកដទៃ ករណីគម្រោងប្លង់នៃសំណង់ ឬសំណង់ដែលខ្លួនសាងសង់នោះមានវិការៈ និងប៉ះពាល់ដល់អ្នកទៃ លើកលែងអ្នកសាងសង់ ឬអ្នកសិក្សាគម្រោងប្លង់ បង្ហាញភស្តុតាងថាការសាងសង់ឬគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។[5]

ជារួមយោងតាមច្បាប់ស្តីពីសំណង់ អ្នកសិក្សាគម្រោងប្លង់ ដែលបានសិក្សានិងអនុវត្តគម្រោងប្លង់របស់ខ្លួនដោយពុំអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបង្កឱ្យមានរបួសស្នាមឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២០ លានរៀល ទៅ ៤០ លានរៀល។

**សម្រាប់វិស្វករ និងស្ថាបត្យករ៖** ស្ថាបត្យករ និងវិស្វករ អាចប្រកបអាជីវកម្មរបស់ខ្លួនដោយស្របច្បាប់ បន្ទាប់ពីខ្លួនបានទទួលការអនុញ្ញាតត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ចជាមុន។[6] ករណីវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់បំពេញមុខងាររបស់ខ្លួនជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយពុំបានចុះបញ្ជីត្រឹមត្រូវ តាមបទប្បញ្ញត្តិច្បាប់ជាធរមាននោះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤ លានរៀល ទៅ ១០ លានរៀល ហើយថែមទាំងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ ក្នុងករណីវិស្វករ ឬស្ថាបត្យកររូបនេះនៅតែបន្តប្រព្រឹត្តបទល្មើសដដែលៗនេះ។

### ២.៣.វិធានការចំពោះម្ចាស់សំណង់ អ្នកសាងសង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន

**សម្រាប់អ្នកសាងសង់៖** អ្នកសាងសង់សំណង់គ្រប់ប្រភេទ ព្រមទាំងអ្នកម៉ៅការសាងសង់ផងត្រូវធានាឱ្យបាននូវការគោរពតាមលិខិតបទដ្ឋានបច្ចេកទេសសំណង់ និងតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយត្រូវប្រើប្រាស់សម្ភារៈបរិក្ខារ គ្រឿងចក្រ ឱ្យបានត្រឹមត្រូវ និងតាមបទបញ្ជាផ្ទៃក្នុង ឬការណែនាំនានានៅក្នុងការដ្ឋានសំណង់នីមួយៗ ពោលគឺរាល់ការសាងសង់ត្រូវ

[5] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ម.៧៦ ។
[6] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ម.១២ និង ម.១៣។


www.theflaglawyer.com

មានសម្ភារៈបរិក្ខារគ្រប់គ្រាន់ និងត្រូវរៀបចំឱ្យមានច្រកចេញចូលសុវត្ថិភាព ព្រមទាំងសម្ភារៈការពារសុវត្ថិភាពឱ្យបានត្រឹមត្រូវ ទាំងសម្រាប់ក្រុមជាងអ្នកសាងសង់ ទាំងសម្រាប់ម្ចាស់សំណង់ ឬអ្នកពាក់ព័ន្ធដែលចូលទៅពិនិត្យទីតាំងសាងសង់សំណង់របស់ខ្លួន។

អ្នកសាងសង់ទាំងអស់ ត្រូវរៀបចំការដ្ឋានសំណង់ឱ្យមានសណ្តាប់ធ្នាប់ និងអនាម័យល្អ ដោយត្រូវហ៊ុំព័ទ្ធរបង និងសំណាញ់ការពារជុំវិញការដ្ឋាន និងត្រូវឱ្យមានច្រកចេញចូល និងបំពាក់ភ្លើងបំភ្លឺសញ្ញាសម្គាល់ការដ្ឋាន និងសញ្ញាឱ្យមានការប្រុងប្រយ័ត្នការគ្រោះថ្នាក់ផងដែរ ដើម្បីអាចការពារពីការប៉ះពាល់ដល់សុខសុវត្ថិភាពរបស់កម្មករសំណង់របស់ខ្លួន ក៏ដូចជាសាធារណជនទូទៅដែលបានឆ្លងកាត់ទីតាំងការដ្ឋានសំណង់របស់ខ្លួន។ ករណីការដ្ឋានសំណង់មានទំហំធំគឺតម្រូវឱ្យមានកម្មករសម្រាប់ផ្តល់សញ្ញាចរាចរណ៍ ឬបញ្ជាក់អំពីការប្រុងប្រយ័ត្ននៅបរិវេណការដ្ឋានដែលកំពុងសាងសង់ ហើយកម្មករសំណង់ពុំត្រូវធ្វើការងារ ឬរក្សាទុកសម្ភារៈបរិក្ខារសំណង់ណាមួយនៅតាមដងផ្លូវសាធារណៈឡើយ។[7]

ករណីមានកំទេចផ្កាភ្លើងដែលអាចធ្វើឱ្យមានការឆាបឆេះក្នុងការដ្ឋានសំណង់ ឬកំទេចកំទីណាមួយ រួមទាំងធូលីដែលកើតចេញពីការសាងសង់ ឬបញ្ហានានាកើតចេញពីការដ្ឋានសំណង់ដូចជាធ្លាក់វត្ថុពីលើទីខ្ពស់ឬដំបូល និងសូរសំឡេងខ្លាំង។ល។ ដែលនាំឱ្យប៉ះពាល់ដល់អ្នកជិតខាង និងសាធារណជនទូទៅដែលឆ្លងកាត់ទីតាំងការដ្ឋានសំណង់នេះ នោះអ្នកសាងសង់ ត្រូវទទួលខុសត្រូវចំពោះជនរងគ្រោះ ដែលរងផលប៉ះពាល់ពីគ្រោះថ្នាក់ ឬបញ្ហាកើតចេញពីការដ្ឋានសំណង់របស់ខ្លួន ព្រមទាំងទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

លើសពីនេះទៀត បុគ្គលដែលប្រើប្រាស់សម្ភារៈបរិក្ខារសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដោយពុំអនុលោមតាមការតម្រូវនិងតាមលក្ខខណ្ឌបច្ចេកទេសសំណង់ ឬអ្នកសាងសង់ដែលប្រើប្រាស់សម្ភារៈបរិក្ខារសំណង់ពុំត្រឹមត្រូវតាមលក្ខខណ្ឌបច្ចេកទេសសំណង់ ឬដែលបានសាងសង់ឬរុះរើសំណង់ ដោយពុំអនុលោមតាមគម្រោងប្លង់ និងតាមបទប្បញ្ញត្តិបច្ចេកទេសំណង់ ឬសាងសង់ឬរុះរើខុសពីលិខិតអនុញ្ញាតដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ហើយដែលបណ្តាលឱ្យមានរបួស ឬប៉ះពាល់ដល់សុខភាព

[7] អនុបណ្ឌិតវិស្វករសំណង់ស៊ីវិល និងឧស្សាហកម្ម លោក **ជីវ ស៊ីវផេង** ប្រធាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកដទៃ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២០ លានរៀល ទៅ ៤០ លានរៀល។[8]

**សម្រាប់ម្ចាស់សំណង់៖** ច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានតម្រូវឱ្យម្ចាស់សំណង់ទាំងអស់ ទាំងសំណង់ចាស់ ទាំងសំណង់ថ្មី ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ឱ្យបានត្រឹមត្រូវតាមការកំណត់ និងតាមបទប្បញ្ញត្តិច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មុននឹងធ្វើការប្រើប្រាស់ និងចាត់ចែងលើសំណង់របស់ខ្លួន ដែលការតម្រូវនេះគឺធ្វើឡើងក្នុងគោលបំណងដើម្បីធានាដល់សន្តិសុខ សុវត្ថិភាព ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់អ្នកប្រើប្រាស់សំណង់ និងសាធារណជនទូទៅ ក៏ដូចជាដើម្បីគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ឱ្យបានគ្រប់ជ្រុងជ្រោយផងដែរ។[9]

ករណីមានបុគ្គល ឬអ្នកវិជ្ជាជីវៈណាមួយ ពុំអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ស្តីពីសំណង់ ឬអនុក្រឹត្យស្តីពីការកំណត់លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ខាងលើនេះ នោះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងត្រូវទទួលទណ្ឌកម្មដូចជាការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ការហាមឃាត់ការប្រើប្រាស់សំណង់ក្នុងគោលដៅក្រៅពីលំនៅឋាន ការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម និងការពិន័យអន្តរការណ៍នានាតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

អាជ្ញាធរមានសមត្ថកិច្ចអាចព្យួរ ឬដកហូតនូវវិញ្ញាបនបត្រប្រើប្រាស់សំណង់តែម្តងករណីរកឃើញថាសំណង់នោះពុំមានសុវត្ថិភាពក្នុងការប្រើប្រាស់ ឬជាប្រភេទសំណង់ដែលមានគ្រោះថ្នាក់ដែលសំណង់ ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់ម្ចាស់សំណង់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

លើសពីនេះទៀត អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិអំណាចហាមឃាត់ការចាត់ចែងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់ ការប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋាន ឬការផ្សព្វផ្សាយពាណិជ្ជកម្ម ចំពោះសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ សំណង់ដែលម្ចាស់សំណង់

[8] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩, ម.២២ និង ម.៩៨ ។

[9] អនុក្រឹត្យ ២២៦ ស្តីពីការកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រ ប្រើប្រាស់សំណង់ អនុម័តនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។

ឬអ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ មិនបានអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច។[10]

សម្រាប់ករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ដូចជា តម្រូវឱ្យជួសជុល ឬកែប្រែសំណង់ កម្រិតការប្រើប្រាស់សំណង់ ហាមឃាត់ការប្រើប្រាស់សំណង់ ហ៊ុមព័ទ្ធសំណង់ ការហាមចូលទីតាំងសំណង់ ការកំណត់បរិវេណសុវត្ថិភាព ការជម្លៀស ព្រមទាំងការតម្រូវឱ្យរុះរើសំណង់ទាំងមូល ឬមួយផ្នែកទៅតាមកម្រិតហានិភ័យនៃគ្រោះថ្នាក់នៃសំណង់នីមួយៗ ហើយអាជ្ញាធរមានសមត្ថកិច្ចក៏មានសិទ្ធិធ្វើការរុះរើសំណង់មានគ្រោះថ្នាក់ទាំងអស់នេះដោយផ្ទាល់បានផងដែរ ទោះបីពុំមានការយល់ព្រមណាមួយ ពីម្ចាស់សំណង់ក្តី។

ជារួម ករណីដែលម្ចាស់សំណង់ប្រើប្រាស់សំណង់អគារណាមួយ ដោយពុំមានឯកសារផ្លូវច្បាប់ ពិសេសវិញ្ញាបនបត្រប្រើប្រាស់សំណង់ នោះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងទទួលរងទណ្ឌកម្មរដ្ឋបាលនានាដូចបានបញ្ជាក់ជូនខាងលើនេះ ករណីដែលសំណង់នេះបង្កជាបញ្ហាណាមួយទៅដល់អ្នកដទៃ។ ក្រៅពីការដាក់ទណ្ឌកម្មនេះ តាមច្បាប់ស្តីពីសំណង់ ម្ចាស់សំណង់ក៏ត្រូវទទួលទណ្ឌកម្មដោយផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២០ លានរៀល ទៅ ៤០ លានរៀល ផងដែរ ករណីដែលម្ចាស់សំណង់ប្រើប្រាស់ដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួស ឬបណ្តាលឱ្យខូចសុខភាពដល់អ្នកទៃ។[11]

**សម្រាប់អ្នកប្រើប្រាស់សំណង់ និងសាធារណជនទូទៅ៖** អំឡុងពេលនៃការប្រើប្រាស់សំណង់ ទាំងក្នុងអំឡុងពេលនៃការសាងសង់ ទាំងក្រោយពេលនៃការសាងសង់ អ្នកប្រើប្រាស់សំណង់ ត្រូវចូលរួមទទួលខុសត្រូវផងដែរចំពោះអ្នកដែលទទួលរងផលប៉ះពាល់ ដែលកើតចេញពីសកម្មភាពរបស់ខ្លួន ហើយអ្នកដំណើរឆ្លងកាត់ទីតាំងការដ្ឋានសំណង់ ឬសំណង់ ដែលបង្កឱ្យមានបញ្ហាគ្រោះថ្នាក់កើតមានឡើង នាំឱ្យប៉ះពាល់ដល់សំណង់អគារ ក៏ដូចជាប៉ះពាល់ដល់សុខសុវត្ថិភាពរបស់អ្នករស់នៅជិតទីតាំងការដ្ឋានសំណង់ ឬសំណង់ នោះអ្នកដែលបង្កបញ្ហានេះក៏ត្រូវទទួលខុសត្រូវផងដែរចំពោះសកម្មភាពរបស់ខ្លួន ទាំងចំពោះការដ្ឋានសំណង់ ម្ចាស់សំណង់ ទាំង

[10] អនុក្រឹត្យលេខ ២២៦ ស្តីពីការកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ អនុម័តនៅថ្ងៃ៣០ ខែធ្នូ ឆ្នាំ២០២០ ។

[11] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩, ម.១០២ ។

ចំពោះជនរងគ្រោះដទៃទៀតផងដែរ។ អ្នកប្រើប្រាស់សំណង់ ក៏ដូចជាអ្នកដំណើរឆ្លងកាត់ទីតាំងការដ្ឋានសំណង់ឬសំណង់ អាចរួចផុតអំពីការចោទប្រកាន់ និងរួចផុតពីការទទួលខុសត្រូវនានាពាក់ព័ន្ធនឹងបញ្ហាគ្រោះថ្នាក់នេះ ករណីអ្នកប្រើប្រាស់សំណង់ អ្នកដំណើរ មានភស្តុតាងផ្សេងបញ្ជាក់ថា ខ្លួនពុំជាប់ពាក់ព័ន្ធនឹងបញ្ហាគ្រោះថ្នាក់ដែលកើតមានខាងលើនេះ។

ដូច្នេះ រាល់គ្រោះថ្នាក់កើតមានឡើង ទាំងក្នុងអំឡុងពេលសាងសង់ ឬក្រោយការសាងសង់ អ្នកប្រព្រឹត្តអំពើល្មើស និងបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ត្រូវទទួលខុសត្រូវចំពោះជនរងគ្រោះផង និងចំពោះមុខច្បាប់ជាធរមានផង។ ជាក់ស្តែងនៅក្នុងពេលអនុវត្តគម្រោងសាងសង់ ឬរុះរើ ម្ចាស់សំណង់ និងអ្នកសាងសង់ឬរុះរើ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ករណីដែលការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ ឬពុំអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បបញ្ញត្តិច្បាប់ជាធរមាន។ សម្រាប់សំណង់ដែលសង់រួចរាល់ ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ ឬការគ្រប់គ្រងសំណង់នោះមានវិការៈ ពុំត្រឹមត្រូវទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។[12]

លើសពីនេះទៀត ទាក់ទងនឹងការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដីនេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ បានបញ្ជាក់ផងដែរថាក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬការគ្រប់គ្រងសំណង់នោះមានវិការហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធិករនៃសំណង់ (ម្ចាស់សំណង់) ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ដោយបន្ទុកនៃការទទួលខុសត្រូវនេះ គឺត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈនៃការសាងសង់ ឬការគ្រប់គ្រងសំណង់។ ប៉ុន្តែក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវនេះបាន។[13]

ក្រៅពីការទទួលខុសត្រូវដោយរូបវន្តបុគ្គល ដូចបញ្ជាក់ខាងលើ នីតិបុគ្គលក៏ត្រូវទទួលខុសត្រូវផងដែរ ពិសេសករណីនីតិបុគ្គលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយពុំមាន

---

[12] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩, ម.៧៧ និង ម.៧៩ ។

[13] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, ម.៧៥៣ ។



www.theflaglawyer.com

អាជ្ញាបណ្ណត្រឹមត្រូវ នោះនីតិបុគ្គលនេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០ លានរៀល ដល់ ៨០ លានរៀល។ នីតិបុគ្គលនេះ ក៏អាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុង មាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលនីតិបុគ្គលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសំណង់។[14]

បន្ថែមលើវិធានការ ដែលអាជ្ញាធរមានសមត្ថកិច្ចបានដាក់ទណ្ឌកម្មចំពោះគ្រប់ភាគីពាក់ព័ន្ធនឹងវិស័យសំណង់ រួមមានម្ចាស់សំណង់ អ្នកសាងសង់ អ្នកគ្រប់គ្រងសំណង់ អ្នកប្រើប្រាស់សំណង់ ដូចបានបញ្ជាក់ក្នុងចំណុច ២.១ ចំណុច ២.២ និងចំណុច ២.៣ ខាងលើ ក្នុងករណីអំពើល្មើសទាំងអស់នេះបណ្តាលឱ្យមានការកាត់អវយវៈ ឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ នោះអំពើល្មើសដូចបានរៀបរាប់ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ។ លើសពីនេះទៀត ករណីអំពើនេះបណ្តាលឱ្យមានមនុស្សស្លាប់ នោះទំហំល្មើសនឹងបទប្បញ្ញត្តិច្បាប់ជាធរមានទាំងអស់នេះ គឺត្រូវផ្តន្ទាទោសចាប់ពី ៧ ឆ្នាំ រហូតដល់ ១០ ឆ្នាំ។[15]

## ៣.សិទ្ធិ និងកិច្ចការពារដល់ជនរងគ្រោះក្នុងវិស័យសំណង់

ករណីមានផលប៉ះពាល់ណាមួយដូចជា ធ្លាក់សម្ភារៈបរិក្ខារ ធូលី ឬសំឡេងរំខាន ឬសកម្មភាពរំខានណាមួយ បណ្តាលមកពីសកម្មភាពសាងសង់ក្នុងការដ្ឋានសំណង់ ឬសំណង់ ឬមានបញ្ហាគ្រោះថ្នាក់ណាមួយកើតមានឡើងលើកម្មករសំណង់ក្នុងការដ្ឋានសំណង់ ឬសាធារណជនទូទៅ ដែលឆ្លងកាត់ទីតាំងការដ្ឋានសំណង់ ឬប៉ះពាល់ដល់អ្នករស់នៅក្បែរការដ្ឋានសំណង់ ឬសំណង់ ទាំងក្នុងអំឡុងពេលនៃការសាងសង់ ទាំងក្រោយពេលការសាងសង់នោះបុគ្គលដែលទទួលរងផលប៉ះពាល់ ឬគ្រោះថ្នាក់ ពាក់ព័ន្ធនឹងសកម្មភាពសាងសង់នៅក្បែរការដ្ឋានសំណង់ឬសំណង់នេះ មានសិទ្ធិទាមទារសំណងនៃការខូចខាត ចេញថ្លៃការព្យាបាល ឬជួសជុលសម្ភារៈដែលខូចខាតទៅកាន់ម្ចាស់សំណង់ អ្នកសាងសង់ អ្នកគ្រប់គ្រងសំណង់ អ្នកប្រើប្រាសសំណង់ និងអ្នកពាក់ព័ន្ធបាន ហើយការទាមទារនេះពុំទាន់គិតពីការទទួលខុសត្រូវចំពោះមុខច្បាប់ និងទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះអ្នកប្រព្រឹត្តអំពើល្មើសនេះនោះទេ។

[14] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩, ម.១០៥។
[15] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩, ម.១០៣។


www.theflaglawyer.com

បុគ្គលដែលរងការខូចខាត ឬមានការបារម្ភជាក់ស្តែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិ ឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីធ្វើការសម្រុះសម្រួលមុននឹងប្តឹងទៅតុលាការ។ ដោយសំណើនេះត្រូវធ្វើក្នុងរយៈពេល ៦០ ថ្ងៃ គិតពីថ្ងៃទទួលរងផលប៉ះពាល់ ហើយគណៈកម្មការដោះស្រាយវិវាទសំណង់ ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល ៦០ ថ្ងៃផងដែរ គិតពីថ្ងៃទទួលពាក្យសុំ។[16] យោងតាមខ្លឹមសារនៃមាត្រានេះ ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅស្ថាប័នផ្សេងទៀតផងដែរ ព្រោះបញ្ញត្តិនេះបានបញ្ជាក់ច្បាស់ថាបុគ្គលដែលរងការខូចខាតអាចធ្វើសំណើ ពុំមែនជាបទប្បញ្ញត្តិតម្រូវឱ្យភាគីរងគ្រោះនេះ ត្រូវតែដាក់ពាក្យសុំមកគណៈកម្មការដោះស្រាយវិវាទសំណង់នេះនោះទេ។ ទោះបីយ៉ាងនេះក្តី ភាគីពាក់ព័ន្ធនឹងការទាមទារសំណង់នេះគួរពិចារណា និងសាកសួរផ្លូវការទៅអាជ្ញាធរមានសមត្ថកិច្ចជាមុន ដើម្បីជៀសវាងការខាតប្រយោជន៍ណាមួយចំពោះខ្លួន។

ករណីពុំមានការទទួលខុសត្រូវ ឬសងសំណងខូចខាតណាមួយទេ បុគ្គលដែលទទួលរងផលប៉ះពាល់ ឬគ្រោះថ្នាក់នេះ អាចដាក់បណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចបានគ្រប់ពេលវេលាដូចជាអាជ្ញាធរមូលដ្ឋានដើម្បីជួយសម្របសម្រួល ឬអាជ្ញាធរជំនាញពាក់ព័ន្ធនឹងវិស័យសំណង់ ឬអាចដាក់បណ្តឹងទៅកាន់តុលាការមានសមត្ថកិច្ចតែម្តង។

គួរកត់សម្គាល់ផងដែរថា សិទ្ធិទាមទារសំណងនៃការខូចខាត ដែលបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាលក្នុងរយៈពេល ៣ ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងខូចខាត ឬក្នុងរយៈពេល ១០ ឆ្នាំ បានកន្លងហួស បន្ទាប់ពីការខូចខាតបានកើតឡើង។[17]

## ៤.នីតិវិធីនៃការដោះស្រាយវិវាទ និងការតវ៉ាចំពោះការដាក់វិធានការតាមផ្លូវច្បាប់

បុគ្គល ឬមន្ត្រីរាជការសាធារណៈ ដែលទទួលរងនូវការប្តឹងផ្តល់ ឬចោទប្រកាន់ណាមួយពាក់ព័ន្ធនឹងការបំពេញកិច្ចការងាររបស់ខ្លួន អាចដាក់បណ្តឹងទៅស្ថាប័នសាមីរបស់ខ្លួនបានក្នុងករណី

---

[16] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ម.៨៦ ។
[17] ច្បាប់ស្តីពីសំណង់ អនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ម.៨០ ។


www.theflaglawyer.com

ដែលខ្លួនពុំសុខចិត្ត ឬពុំបានប្រព្រឹត្តដូចការចោទប្រកាន់ ដើម្បីស្នើសុំឱ្យស្ថាប័នរបស់ខ្លួនជួយរកដំណោះស្រាយ។

ក្នុងវិស័យសំណង់ ករណីដែលបុគ្គល ឬអ្នករាជការសាធារណៈណាពុំសុខចិត្តនឹងការប្តឹងផ្តល់ ឬការចោទប្រកាន់ណាមួយមកលើខ្លួន នោះបុគ្គល ឬអ្នករាជការសាធារណៈនេះអាចប្តឹងតវ៉ាទៅអាជ្ញាធរឬស្ថាប័នដែលមានសមត្ថកិច្ចបាន ដើម្បីឱ្យជួយរកដំណោះស្រាយជូនខ្លួន។ ជាក់ស្តែង មាត្រា ៨៣ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ បានចែងថា បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ និងជាប់ពាក់ព័ន្ធជាមួយនឹងសេចក្តីសម្រេចណាមួយរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិដាក់ពាក្យសុំតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល ៦០ ថ្ងៃ គិតពីថ្ងៃដែលទទួលបានលិខិតជូនដំណឹងអំពីការចេញសេចក្តីសម្រេចនោះ។

ករណីបុគ្គល ឬអ្នករាជការសាធារណៈណាដែលពុំពេញចិត្តចំពោះសេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ារបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចពុំសម្រេចលើបណ្តឹងតវ៉ារបស់ខ្លួន ម្ចាស់បណ្តឹងអាចប្តឹងបន្តទៅកាន់តុលាការមានសមត្ថកិច្ចបានក្នុងរយៈពេល ៣០ ថ្ងៃ គិតពីថ្ងៃផុតរយៈពេលកំណត់នៃសមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ារបស់ខ្លួន ដែលបានដាក់ចូលទៅអាជ្ញាធរមានសមត្ថកិច្ចនោះ។

ការអនុញ្ញាតឱ្យមានការប្តឹងតវ៉ានេះ ពិតជាមានសារៈសំខាន់សម្រាប់ភាគីដែលទទួលរងការពិន័យ និងការដាក់វិធានការផ្លូវច្បាប់ណាមួយមកលើខ្លួន ដើម្បីអាចទុកពេលវេលា និងឱកាសសម្រាប់សាមីខ្លួនអាចបកស្រាយ និងយកភស្តុតាងពាក់ព័ន្ធនានាមកបង្ហាញជូនអាជ្ញាធរមានសមត្ថកិច្ចដើម្បីស្វែងយល់ និងរកយុត្តិធម៌ជូនភាគីទាំងសងខាង។

## ៥.សេចក្តីសន្និដ្ឋាន

គ្រប់សកម្មភាពរបស់ភាគីពាក់ព័ន្ធនឹងវិស័យសំណង់ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ និងវិធានច្បាប់ផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យសំណង់នេះ ដែលលិខិតបទដ្ឋានគតិយុត្តទាំងអស់នេះជួយធានាឱ្យបាននូវការអភិវឌ្ឍអចលនវត្ថុ និងការសាងសង់សំណង់នៅព្រះរាជាណាចក្រកម្ពុជាប្រកបដោយគុណភាព ព្រមទាំងជួយធានាដល់សន្តិសុខសុវត្ថិភាពសម្រាប់ម្ចាស់សំណង់ ក៏ដូចជាអ្នកប្រើប្រាស់សំណង់ផងដែរ ពិសេសជួយ

ធានា និងពង្រឹងដល់ការអនុវត្តច្បាប់ និងការទទួលខុសត្រូវចំពោះមុខច្បាប់លើសកម្មភាពនានាក្នុងវិស័យសំណង់។

ជារួម ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ភាគីពាក់ព័ន្ធនៅក្នុងវិស័យសំណង់ក៏ដូចជាដើម្បីជៀសផុតអំពីការទទួលខុសត្រូវចំពោះវិធានការផ្លូវច្បាប់ណាមួយ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ មន្ត្រីអនុវត្តច្បាប់ ម្ចាស់សំណង់ អ្នកសាងសង់ អ្នកគ្រប់គ្រងសំណង់ អ្នកជួលសំណង់ អ្នកអភិវឌ្ឍ អ្នកប្រើប្រាស់សំណង់ និងសាធារណជនទូទៅ ត្រូវបន្តអនុវត្តនិងគោរពច្បាប់ជាធរមានឱ្យបានខ្ជាប់ខ្ជួន ពិសេសត្រូវស្នើសុំឱ្យមានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាជាមុនសិន មុននឹងធ្វើសកម្មភាពណាមួយលើវិស័យសំណង់ ឬគម្រោងសាងសង់របស់ខ្លួន៕